# ទូតជាតក



*ព្រះសាស្ដា កាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធការសរសើរបញ្ញា របស់ព្រះអង្គ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ទូតេ តេ ព្រហ្មេ ចាហេសឹ** *ដូច្នេះជាដើម ។*

*ភិក្ខុទាំងឡាយញ៉ាំងកថា ឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ អ្នកទាំងឡាយចូរមើលការឈ្លាស ក្នុងឧបាយរបស់ព្រះទសពលចុះ ព្រះអង្គសម្ដែងពួកស្រីទេពអប្សរដល់ព្រះនន្ទសក្យបុត្រ ហើយប្រទានព្រះអរហត្ត, ទ្រង់ប្រទានសំពត់ចាស់ដល់ព្រះចូឡបន្ថក: ហើយប្រទានព្រះអរហត្តមួយអន្លើដោយបដិសម្ភិទា, ទ្រង់សម្ដែងផ្កាបទុមដល់ព្រះកម្មារបុត្រហើយ ប្រទាណព្រះអរហត្ត, ទ្រង់ទូន្មានសត្វដោយឧបាយផ្សេងៗយ៉ាងនេះ ។ ព្រះសាស្ដាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នារឿងអ្វី ? កាលពួកភិក្ខុពោលថា រឿងឈ្មោះនេះ ទ្រង់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែល*

តថាគតជាអ្នកឈ្លាសក្នុងឧបាយថា វត្ថុនេះជាយ៉ាងនេះ សូម្បីកាលមុន តថាគតក៏ជាអ្នកឈ្លាសក្នុងឧបាយដែរ ដូច្នេះហើយ ព្រះអង្គនាំយកអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ជនបទក្លាយទៅកន្លែងមិនមានប្រាក់ ។ (ព្រោះ) ព្រះរាជានោះបៀតបៀនអ្នកជនបទ រឹបអូសយកទ្រព្យសម្បត្តិ ។ កាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាសិគ្រាម ពេលចម្រើនវ័យធំហើយ ទៅកាន់នគរតក្កសិលា ពោលនឹងអាចារ្យថា ខ្ញុំនឹងត្រាច់សូមគេដោយធម៌ ហើយនាំទ្រព្យជាចំណែកអាចារ្យតាមក្រោយ ដូច្នេះហើយ ក៏បានសិក្សារៀនសូត្រ កាលបានសម្រេចវិជ្ជាហើយ ទើបឲ្យអនុយោគ និងប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំនឹងនាំទ្រព្យជាចំណែកអាចារ្យដល់លោក ដូច្នេះទើបចេញទៅ កាលត្រាច់ទៅកាន់ជនបទ លោកស្វែករកទ្រព្យដោយធម៌ស្មើ ហើយក៏បានមាសផ្កាករ ៧ រួចគិតថា យើងនឹងឲ្យដល់អាចារ្យ ដូច្នេះកាលទៅ ក្នុងរវាងផ្លូវ បានឡើងជិះទូក ដើម្បីឆ្លងទន្លេគង្គា ។

ពេលកំពុងជិះឆ្លង កាលទូកឃ្លេងឃ្លោង ធ្វើឲ្យមាសរបស់លោកធ្លាក់ចុះក្នុងទឹក ។ ព្រះពោធិសត្វគិតថា មាសជារបស់រកបានដោយក្រ កាលយើងស្វែងរកទ្រព្យជាចំណែកអាចារ្យក្នុងជនបទម្តងទៀត នឹងជាការយឺនយូរ បើដូច្នោះ មានតែយើងគប្បីអង្គុយអត់អាហារនៅនឹងច្រាំងទន្លេគង្គានេះឯង ព្រះរាជានឹងដឹងភាពនៃការអង្គុយ របស់យើង ហើយបន្ទាប់មក ទ្រង់នឹងបញ្ជូនពួកអាមាត្យមក យើងនឹងមិននិយាយចរចាជាមួយនឹងអាមាត្យទាំងនោះឡើយ រួចព្រះរាជានឹងយាងមកដោយខ្លួនឯង ដោយឧបាយនេះ យើងនឹងបានទ្រព្យជាចំណែកក្នុងសម្នាក់ព្រះរាជានោះ ។ ព្រះពោធិសត្វដណ្តប់សំពត់ឧត្តរិសាដក រួចតម្កល់អំបោះដើម្បីយញ្ញ អង្គុយនៅនឹងច្រាំងទន្លេគង្គា ហាក់ដូចជារូបបដិមាមាស ដែលនៅនឹងផ្ទៃរខ្សាច់ ដែលមានពណ៌ដូចប្រាក់ ។

មហាជនឃើញព្រះពោធិសត្វអង្គុយអត់អាហារ ហើយសួរថា ព្រោះហេតុអ្វី លោកទើបអង្គុយចឹង ? ព្រះពោធិសត្វមិនប្រាប់អ្នកណាឡើយ ។ ថ្ងៃស្អែក មនុស្សដែលរស់នៅជិតទ្វារស្រុក ស្តាប់នូវភាពដែលព្រះពោធិសត្វអង្គុយក្នុងទីនោះ ទើបនាំគ្នាមក ហើយសួរ

*លោកនៅតែមិនប្រាប់ សូម្បីដល់មនុស្សទាំងនោះ ។ មនុស្សទាំងនោះឃើញព្រះពោធិសត្វមានសេចក្ដីលំបាក នាំគ្នាបរិទេវនាការ ចៀសចេញទៅ ។ ថ្ងៃទី ៣ ពួកអ្នកនគរមក, ថ្ងៃទី ៤ ពួកឥស្សរជនក្នុងព្រះនគរមក, ថ្ងៃទី ៥ ពួករាជបុរសមក ។ ថ្ងៃទី ៦ ព្រះរាជាបញ្ជូនពួកអាមាត្យមក ព្រះពោធិសត្វនៅតែមិននិយាយជាមួយនឹងអាមាត្យទាំងនោះ ។ ថ្ងៃទី ៧ ព្រះរាជាទ្រង់មានសេចក្ដីភ័យខ្លាច ទើបយាងទៅកាន់សម្នាក់ព្រះពោធិសត្វ កាលនឹងសាកសួរ ទើបត្រាស់គាថាទី ១ ថា*

ទូតេ តេ ព្រហ្មេ ចាហេសុំ, គង្គាតីរស្មិ ឈាយតោ;
តេសំ បុដ្ឋោ ន ព្យាកាសិ, ទុក្ខំ គុយ្ហមតំ នុ តេ។

***ម្នាលព្រហ្ម យើងបានបញ្ជូនពួកទូតមកក្នុងសម្នាក់អ្នក ដែលកំពុងសុបសៅ ក្បែរច្រាំងគង្គា ពួកទូតទាំងនោះ បានសួរហើយ តែអ្នកមិនឆ្លើយប្រាប់សោះ សេចក្ដីទុក្ខ (ណា) ដែលកើតឡើងដល់អ្នក សេចក្ដីទុក្ខនោះ ដឹងបានតែអ្នកទេឬ ។***

*ពាក្យថា **សេចក្ដីទុក្ខនោះ ដឹងបានតែអ្នកទេឬ** សេចក្ដីថា ម្នាលព្រាហ្មណ៍ ហេតុអ្វីអេះ សេចក្ដីទុក្ខណាកើតឡើងដល់លោក សេចក្ដីទុក្ខនោះជាសេចក្ដីស្ងាប់ដ៏កំបាំងឬ បានជាលោកមិនប្រាប់ដល់អ្នកដទៃ ។*

*ព្រះមហាសត្វស្ដាប់ពាក្យនោះហើយ ពោលថា បពិត្រមហារាជ ទូលព្រះបង្គំគប្បីប្រាប់ដល់អ្នក ដែលអាចនាំសេចក្ដីទុក្ខ របស់ទូលព្រះបង្គំប៉ុណ្ណោះ មិនប្រាប់ដល់បុគ្គលដទៃ រួចទើបពោល ៧ គាថាថា*

សចេ តេ ទុក្ខមុប្បជ្ជេ, កាសីនំ រដ្ឋវឌ្ឍន;
មា ខោ នំ តស្ស អក្ខាហិ, យោ តំ ទុក្ខា ន មោចយេ។

***បពិត្រព្រះអង្គជាបុគ្គលចម្រើន ក្នុងដែនរបស់អ្នកកាសី បើសេចក្ដីទុក្ខ គប្បីកើតឡើងដល់ព្រះអង្គ បុគ្គលណាដោះទុក្ខនោះ មិនបានទេ សូមព្រះអង្គកុំប្រាប់សេចក្ដីទុក្ខនោះដល់បុគ្គលនោះឡើយ ។***

យោ តស្ស ទុក្ខជាតស្ស, ឯកង្គមបិ ភាគសោ;
វិប្បមោចេយ្យ ធម្មេន, កាមំ តស្ស បវេទយ។

*បុគ្គលណាគប្បីដោះទុក្ខព្រះអង្គនោះបាន ដោយធម៌ ជាចំណែកនៃសេចក្ដីសុខតែម្យ៉ាង សូមព្រះអង្គប្រាប់ដល់បុគ្គលនោះ ដោយពិត ។*

សុវិជានំ សិង្គាលានំ, សកុណានញ្ច វស្សិតំ;
មនុស្សវស្សិតំ រាជ, ទុព្វិជានតរំ តតោ។

*សំឡេងពួកឆ្កែចចកក្ដី ពួកសត្វក្រៀលក្ដី ដឹងបានដោយងាយ បពិត្រមហារាជ ឯសំដីរបស់មនុស្ស ដឹងបានដោយកម្រជាងសម្លេងនោះទៅទៀត ។*

អបិ ចេ មញ្ញតី ចោសោ, ញាតិ មិត្តោ សខាតិ វា;
យោ បុព្វេ សុមនោ ហុត្វា, បច្ឆា សម្បជ្ជតេ ទិសោ។

*មួយទៀត កាលពីមុន បុរសណា មានចិត្តល្អ គេសម្គាល់ថា ជាញាតិសន្ដាន ឬមិត្រសម្លាញ់ តែដល់មកខាងក្រោយ បុរសនោះ ត្រឡប់ទៅជាសត្រូវនឹងគ្នាវិញក៏មាន ។*

យោ អត្តនោ ទុក្ខមជានុបុដ្ឋោ, បវេទយេ ជន្តុ អកាលរូបេ;
អានន្ទិនោ តស្ស ភវន្តិ មិត្តា, ហិតេសិនោ តស្ស ទុខី ភវន្តិ។

*ជនណា មានគេមិនសាកសួរសេចក្ដីទុក្ខរបស់ខ្លួន ហើយនិយាយប្រាប់ (នូវសេចក្ដីកំបាំងរបស់ខ្លួន) ក្នុងកាលមិនគួរ មិត្រទាំងឡាយ ជាអ្នកមិនត្រេកអរចំពោះជននោះក៏មាន ជាអ្នកស្វែងរកនូវប្រយោជន៍ មានសេចក្ដីទុក្ខចំពោះជននោះ ក៏មាន ។*

កាលញ្ច ញត្វាន តថាវិធស្ស, មេធាវិនំ ឯកមនំ វិទិត្វា;
អក្ខេយ្យ តិព្វានិ បរស្ស ធីរោ, សណ្ហំ គិរំ អត្ថវតិំ បមុញ្ចេ។

*អ្នកប្រាជ្ញដឹងនូវកាលគួរ (នឹងនិយាយប្រាប់) ផង ដឹងនូវមេធាវិជនថា មានចិត្តតែមួយជាមួយនឹងខ្លួនផង ទើបគួរប្រាប់នូវសេចក្តីទុក្ខទាំងឡាយ ដល់ជនឯទៀត មានប្រការដូច្នោះ ហើយគប្បីបញ្ចេញនូវពាក្យដ៏ពីរោះ ជាពាក្យមានប្រយោជន៍ ។*

សចេ ច ជញ្ញា អវិសយ្ហមត្តនោ, ន តេ ហិ មយ្ហំ សុខាគមាយ;
ឯកោវ តិព្ពានិ សហេយ្យ ធីរោ, សច្ចំ ហិរោត្តប្បមបេក្ខមានោ។

*អ្នកប្រាជ្ញកាលបើសម្លឹងរំពឹងឃើញនូវហិរិ និងឱត្តប្បៈ ជាក់ច្បាស់ហើយ រមែងដឹងនូវទុក្ខ ដែលខ្លួនពិបាកទ្រាំថា សេចក្តីសុខ ដែលនឹងមានដល់អាត្មាអញ មិនមែនមាន (ព្រោះការលើកធុរៈ ដាក់ទម្ងន់ទៅលើអ្នកដទៃទេ) ហើយក៏អត់ទ្រាំទុក្ខដ៏ខ្លាំងក្លាតែម្នាក់ឯង ។*

*ព្រះមហាសត្វសម្តែងធម៌ ដល់ព្រះរាជាដោយគាថាទាំង ៧ យ៉ាងនេះហើយ កាលនឹងសម្តែងភាពជារកទ្រព្យដើម្បីអាចារ្យរបស់ខ្លួន ទើបពោល ៤ គាថាថា*

អហំ រដ្ឋេ វិចរន្តោ, និគមេ រាជធានិយោ;
ភិក្ខមានោ មហារាជ, អាចរិយស្ស ធនត្ថិកោ។

*បពិត្រមហារាជ ទូលព្រះបង្គំជាអ្នកត្រូវការដោយទ្រព្យ (យកទៅបូជា) ដល់អាចារ្យ ទើបដើរសូមគេក្នុងដែន និគម និងរាជធានី ។*

គហបតី រាជបុរិសេ, មហាសាលេ ច ព្រាហ្មណេ;
អលត្ថំ សត្ត និក្ខានិ, សុវណ្ណស្ស ជជាជិប;
តេ មេ នដ្ឋា មហារាជ, តស្មា សោចាមហំ កុសំ។

*បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ (សូមឲ្យ) ពួកគហបតី ពួករាជបុរស ពួកព្រាហ្មណមហាសាល បានឆ្តោរមាស ៧ បពិត្រមហារាជ ឆ្តោរមាសរបស់ខ្ញុំព្រះអង្គនោះបាត់ ហេតុនោះ បានជាខ្ញុំព្រះអង្គសោកដ៏ក្រៃលែង ។*

បុរិសា តេ មហារាជ, មនសានុវិចិន្តិតា;

**ជាលំ ទុក្ខា បមោចេតុំ, តស្មា តេសំ ន ព្យាហរិំ។**

***បពិត្រមហារាជ ពួករាជបុរសរបស់ព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា មិនអាចដើម្បីជួយដោះខ្ញុំព្រះអង្គ ឲ្យរួចចាកទុក្ខបានទេ ហេតុនោះ ខ្ញុំព្រះអង្គមិនប្រាប់ដល់រាជបុរសទាំងនោះឡើយ ។***

**ត្វញ្ច ខោ មេ មហារាជ, មនសានុវិចិន្តិតោ;**
**អលំ ទុក្ខា បមោចេតុំ, តស្មា តុយ្ហំ បវេទយិំ។**

***បពិត្រមហារាជ ចំណែកព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា ព្រះអង្គអាចជួយដោះទុក្ខបាន ហេតុនោះ ខ្ញុំព្រះអង្គទើបក្រាបទូលដល់ព្រះអង្គ ។***

*ព្រះរាជាស្តាប់ធម្មកថា របស់ព្រះមហាសត្វហើយ ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកកុំគិតច្រើនឡើយ យើងនឹងប្រទានទ្រព្យជារបស់អាចារ្យដល់អ្នក ដូច្នេះហើយ ទ្រង់ក៏បានប្រទានទ្រព្យជាទ្វេគុណ ។*

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ឱសានគាថា (គាថាចុងក្រោយ) ថា*

**តស្សាទាសិ បសន្នត្តោ, កាសីនំ រដ្ឋវឌ្ឍនោ;**
**ជាតរូបមយេ និក្ខេ, សុវណ្ណស្ស ចតុទ្ទស។**

***ព្រះបាទពារាណសី ជាអ្នកចម្រើនក្នុងដែន របស់អ្នកកាសី មានព្រះហឫទ័យជ្រះថ្លា បានប្រទានគ្រឿងមាសសុទ្ធ ចំនួន ១៤ ដុំ ដល់មហាសត្វនោះ ។***

*ព្រះមហាសត្វឲ្យឱវាទដល់ព្រះរាជា និងឲ្យទ្រព្យដល់អាចារ្យរួចហើយ លោកក៏ធ្វើបុណ្យទាំងឡាយមានឲ្យទានជាដើម ចំណែកព្រះរាជាតាំងនៅក្នុងឱវាទ របស់ព្រះមហាសត្វ ទ្រង់សោយរាជសម្បត្តិប្រកបដោយធម៌ សូម្បីអ្នកទាំងពីរក៏បានទៅតាមយថាកម្ម ។*

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីកាលមុន តថាគតក៏ជាឈ្លាសក្នុងឧបាយដែរ ដូច្នេះហើយ ព្រះអង្គប្រជុំជាតកថា

**តទា រាជា អានន្ទោ អហោសិ** ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ

**អាចរិយោ សារិបុត្តោ** អាចារ្យបានមកជាសារីបុត្រ

**ព្រាហ្មណមាណវោ បន អហមេវ អហោសឹ** ចំណែកព្រាហ្មណ៍គឺតថាគត នេះឯង ។

ទូតជាតក ចប់ ។

( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តេរសកនិបាត បិដកលេខ ៥៩ ទំព័រ ២៧៩)

ថ្ងៃ ៧ កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ១៨ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨
ដោយស.ដ.វ.ថ